# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៣

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 09-Apr-2013, 15:19
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

## សេចក្ដីសន្និដ្ឋានអនុលោមតាមវិធាន ៩២ អំពីច្បាប់អនុវត្តលើការទទួលយកជាភស្តុតាងនូវកំណត់ហេតុស្លាប់ចម្លើយ ជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់

---

| ដាក់ដោយ៖ | ដាក់ជូន៖ |
|---|---|
| **មេធាវីការពារក្ដីលោក ខៀវ សំផន** | **អង្គជំនុំជម្រះសាលាដំបូង៖** |
| មេធាវី គង់ សំអុន | ចៅក្រម និល ណុន |
| មេធាវី Anta GUISSÉ | ចៅក្រម Silvia CARTWRIGHT |
| មេធាវី Arthur VERCKEN | ចៅក្រម យូរ ឧត្តរា |
| មេធាវី Jacques VERGÈS | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម យ៉ា សុខន |

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Shéhérazade BOUARFA

កញ្ញា Mathilde CHIFFERT

កញ្ញា អ៊ួច ស្រីផាត

លោក Pierre TOUCHE

កញ្ញា Blandine ZELLER

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្ដីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

## I- សេចក្តីផ្តើម

១. នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ) ប្រកាសទទួលយកជាភ័ស្តុតាងនូវកំណត់ហេតុស្តាប់ចម្លើយសាក្សី ពាក់ព័ន្ធនឹងការជម្លៀសប្រជាជន ដំណាក់កាលទី ១[1]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ភាគីពុំមានសិទ្ធិដាច់ខាត ក្នុងការទាមទារឱ្យអង្គជំនុំជម្រះកោះហៅសាក្សីសក្តានុពលទាំងអស់ឱ្យមកផ្តល់សក្ខីកម្មបានទេ[2]។ ដូច្នេះ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គជំនុំជម្រះទទួលយកជាភ័ស្តុតាងនូវកំណត់ហេតុស្តាប់ចម្លើយ ដោយមិនចាំបាច់កោះហៅម្ចាស់ចម្លើយឱ្យមកផ្តល់សក្ខីកម្មនៅសវនាការ[3]។ មេធាវីការពារក្តីគ្រប់ក្រុមបានជំទាស់ទៅនឹងសំណើសុំនេះ[4]។

២. នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេច ("សេចក្តីសម្រេច ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣)[5] ដោយបញ្ជាក់ថា ចម្លើយពាក់ព័ន្ធនឹងអំពើ ឬអាកប្បកិរិយារបស់

[1] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E96 ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១។

[2] ដូចយោងខាងលើ កថាខណ្ឌ ២។

[3] ដូចយោងខាងលើ។

[4] សារណាឆ្លើយតបទៅនឹងការសន្និដ្ឋានរបស់ ក.ស.ព ទាក់ទងនឹងការទទួលយកកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ឯកសារ E96/1 ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១១ ("សារណាឆ្លើយតបរបស់ នួន ជា"), ចម្លើយតបរបស់ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ ទៅនឹង "សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះអង្គជំនុំជម្រះសាលាដំបូង" ឯកសារ E96/2 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ("ចម្លើយតបរបស់ អៀង ធីរិទ្ធ"), ចម្លើយតបរបស់ អៀង សារី ចំពោះសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងសំណើសុំឱ្យបើកសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ ឯកសារ E96/3 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ("ចម្លើយតបរបស់ អៀង សារី"), សេចក្តីសង្កេតតបទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី ឯកសារ E96/4 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ("ចម្លើយតបរបស់ ខៀវ សំផន")។

[5] សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់

ជនជាប់ចោទ ក៏ដូចជាពាក់ព័ន្ធនឹងបញ្ហាវិវាទរវាងភាគីនៃរឿងក្តី មិនអាចទទួលយកបានទេ ប្រសិនបើភាគី និងអង្គជំនុំជម្រះ មិនអាចសួរដេញដោលម្ចាស់ចម្លើយបាន[6]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះបានសម្រេចថាអាចដាក់ឲ្យពិភាក្សាដេញដោលបាននូវកំណត់ហេតុស្តាប់ចម្លើយ ឬប្រតិចារឹក ប្រសិនបើភ័ស្តុតាងក្រោមទម្រង់នេះ៖ *"ក) មានលក្ខណៈត្រួតគ្នា ដោយសារតែសាក្សីដទៃទៀតនឹងមកផ្តល់សក្ខីកម្ម ឬបានផ្តល់សក្ខីកម្មផ្ទាល់មាត់រួចហើយលើអង្គហេតុស្រដៀងគ្នានេះ ខ) ទាក់ទងនឹងបរិបទប្រវត្តិសាស្ត្រ នយោបាយ ឬយោធា នៃសំណុំរឿង លើកឡើងអំពីអង្គហេតុជាក់លាក់នៃឧក្រិដ្ឋកម្មចោទប្រកាន់ ឬល័ក្ខខ័ណ្ឌទូទៅដែលត្រូវបំពេញដើម្បីឲ្យអំពើចោទប្រកាន់ត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មតាមច្បាប់អន្តរជាតិ គ) មានការវិភាគជាទូទៅ ឬជាស្ថិតិ អំពីសមាសភាពជាតិពន្ធុនៃប្រជាជននៅក្នុងទីតាំងដូចមានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឃ) ពាក់ព័ន្ធនឹងផលប៉ះពាល់នៃឧក្រិដ្ឋកម្មទៅលើជនរងគ្រោះ ង) មិនអាចធ្វើការសួរដេញដោលបាន ដោយសារតែសាក្សីពាក់ព័ន្ធមិនអាចមកផ្តល់សក្ខីកម្មបាន [...]"*[7]។

៣. នៅថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានដាក់សំណើសុំមួយទៀត អមដោយឧបសម្ព័ន្ធចំនួន ៤ សុំដាក់ឲ្យពិភាក្សាដេញដោលនូវកំណត់ហេតុស្តាប់ចម្លើយសាក្សី ពាក់ព័ន្ធនឹងការជម្លៀសប្រជាជន ដំណាក់កាលទី ២[8]។ នៅក្នុងសំណើសុំនោះ សហព្រះរាជអាជ្ញាបានលើកឡើងថា កំណត់ហេតុស្តាប់ចម្លើយទាំងនេះ *"ពាក់ព័ន្ធនឹងបញ្ហាផ្សេងទៀត ក្រៅពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ"* ហើយ *"មិនចូលក្នុងលក្ខណៈវិនិច្ឆ័យបដិសេធភ័ស្តុតាង ដូចមានចែងក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង នោះទេ"*[9]។

៤. នៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានផ្ញើអនុស្សរណៈជូនភាគី ស្នើឲ្យបញ្ជាក់យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០១២ និងអនុលោមតាមលក្ខណៈវិនិច្ឆ័យ ក៏ដូចជាបែបបទ

---

ចម្លើយសាក្សី និងឯកសារនានា នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E96/7 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២។

[6] ដូចយោងខាងលើ កថាខណ្ឌ ២១ និងកថាខណ្ឌ ២២។

[7] ដូចយោងខាងលើ កថាខណ្ឌ ២៤។

[8] សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យទទួលយកចម្លើយសាក្សីនានាដែលទាក់ទងនឹងដំណាក់កាលទី ២ នៃការជម្លៀសប្រជាជន និងបញ្ហាភ័ស្តុតាងផ្សេងទៀត ឯកសារ E208/2 ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១២។

[9] ដូចយោងខាងលើ កថាខណ្ឌ ៥។

ដូចមានចែងនៅក្នុងសេចក្តីសម្រេច ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ ថា តើកំណត់ហេតុស្តាប់ចម្លើយណាខ្លះ នៅក្នុងបញ្ជីឯកសារដាក់នៅពេលបើកការជំនុំជម្រះក្តី ដែលភាគីចង់ឱ្យអង្គជំនុំជម្រះទទួលយកជាភ័ស្តុតាង ពាក់ព័ន្ធនឹងការជម្លៀសប្រជាជន ដំណាក់កាលទី ១ និងទី ២[10]។

៥. នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានដាក់សំណើបន្ថែមមួយទៀត អមដោយឧបសម្ព័ន្ធចំនួន ១៦ សុំដាក់ឱ្យពិភាក្សាដេញដោលនូវកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកចម្លើយសាក្សី ("សំណើបន្ថែម")[11]។

៦. នៅថ្ងៃដដែលនោះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សារណា តបទៅនឹងសេចក្តីសម្រេច ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២[12]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានគូសបញ្ជាក់ជាអាទិ៍ថា ទោះជាក្នុងករណីណាក៏ដោយ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនអាចយកមកប្រៀបធៀបជាមួយកំណត់ហេតុស្តាប់ចម្លើយសាក្សី ឬពាក្យបណ្តឹងបានឡើយ ហើយដោយសារតែឋានៈពិសេសនេះ ទើបការដាក់ឯកសារប្រភេទនេះមិនអាចត្រូវបានកម្រិតត្រឹមតែ "គំរូតំណាង" នោះទេ[13]។

៧. នៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ មេធាវីការពារក្តីលោក ខៀវ សំផន បានជំទាស់ទៅនឹងការដាក់កំណត់ហេតុស្តាប់ចម្លើយច្រើនពេក សម្រាប់ពិភាក្សាដេញដោលចំពោះមុខអង្គជំនុំជម្រះ[14]។

---

[10] អនុស្សរណៈស្តីពីសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឱ្យទទួលយកចម្លើយសាក្សី ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី ១ និងទី ២ ឯកសារ E208/3 ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២។

[11] សំណើបន្ថែមរបស់សហព្រះរាជអាជ្ញាដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងប្រតិចារឹក ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ពី ១-១៦ ឯកសារ E96/8 ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២។

[12] សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងអនុស្សរណៈ E208/3 និងសេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានា នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង E96/7 ដោយរួមបញ្ចូលទាំងឧបសម្ព័ន្ធសម្ងាត់ទី ១ និងទី ២ ឯកសារ E208/4 ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២។

[13] ដូចយោងខាងលើ កថាខណ្ឌ ៩-១៥។

[14] មតិគាំទ្រសំណើរបស់លោក អៀង សារី E221 និងស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូងឱ្យបង្គាប់ដល់សហព្រះរាជអាជ្ញាធ្វើការកែតម្រូវបញ្ជីសក្ខីកម្មជាលាយលក្ខណ៍អក្សរ ដែលសហព្រះរាជអាជ្ញាមានបំណងដាក់បញ្ចូលក្នុងការពិភាក្សាដេញដោល

យើងខ្ញុំបានសង្កត់ធ្ងន់ជាអាទិ៍ថា ត្រូវតែមានការប្រយ័ត្នប្រយែងចំពោះភាពអាចជឿទុកចិត្តបាននៃកំណត់ហេតុស្តាប់ចម្លើយ ដែលម្ចាស់ចម្លើយនឹងមិនត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្ម នៅក្នុងសវនាការ[15]។ យើងខ្ញុំក៏បានគូសបញ្ជាក់ផងដែរថា កំណត់ហេតុស្តាប់ចម្លើយមួយចំនួនធំចេញក្រៅវិសាលភាពនៃការជំនុំជម្រះក្តីលើសំណុំរឿង ០០២/០១ និងមិនត្រូវបានបកប្រែនោះទេ[16]។

៨. នៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានចេញអនុស្សរណៈ ដោយបាន ១) ជម្រាបដល់សហព្រះរាជអាជ្ញាថា មានតែកំណត់ហេតុស្តាប់ចម្លើយ ដែលមានជាភាសាផ្លូវការទាំងអស់របស់ អ.វ.ត.ក នៅមុនថ្ងៃ សុក្រ ទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៣ ប៉ុណ្ណោះ ទើបអាចស្នើសុំដាក់ជាភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះបាន[17] និង ២) ជូនដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណីថាពួកគេមានពេលរហូតដល់ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣ ដើម្បីផ្តល់សេចក្តីបញ្ជាក់ថាតើឯកសារនីមួយដែលពួកគេស្នើសុំដាក់ មានគោលដៅបង្ហាញអ្វីខ្លះ និងចង្អុលបង្ហាញថាតើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីណាខ្លះដែលពួកគេចង់ស្នើសុំដាក់ជាភ័ស្តុតាង[18]។

៩. នៅថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ មេធាវីការពារក្តីលោក នួន ជា បានឆ្លើយតបទៅនឹងសំណើបន្ថែមរបស់សហព្រះរាជអាជ្ញា សុំដាក់ឲ្យពិភាក្សាដេញដោលនូវកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកចម្លើយសាក្សី[19]។ ក្នុងចម្លើយតបនោះ មេធាវីការពារក្តីលោក នួន ជា បានលើកឡើងនូវទឡ្ហីករណ៍មួយចំនួន ពាក់ព័ន្ធនឹងរបបគតិយុត្តិស្តីពីការគ្រប់គ្រងការទទួលយកកំណត់ហេតុស្តាប់

---

ជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ ឯកសារ E223 ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២។

[15] ដូចយោងខាងលើ កថាខណ្ឌ ៩។

[16] ដូចយោងខាងលើ កថាខណ្ឌ ២០។

[17] អនុស្សរណៈស្តីពីសវនាការដេញដោលលើឯកសារនាពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ប្រើប្រាស់នៅសវនាការ (ឯកសារ E208/4) និងសំណើរបស់មេធាវីការពារជនជាប់ចោទខៀវ សំផន ស្នើសុំកែតម្រូវបញ្ជីភ័ស្តុតាងគាំទ្រ ឯកសារ E223/2 ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ កថាខណ្ឌ ៩។

[18] ដូចយោងខាងលើ កថាខណ្ឌ ១៣។

[19] ការឆ្លើយតបជាបឋមទៅនឹងសំណើបន្ថែមរបស់សហព្រះរាជអាជ្ញាសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងប្រតិចារឹក ឯកសារ E96/8/1 ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១២។

ចម្លើយ ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ ដែលអនុវត្ត នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងជារបបគតិយុត្តិដែលអង្គជំនុំជម្រះបានប្រកាសថាអាចយកមកអនុវត្តបាន នៅក្នុងសំណុំរឿង ០០២/០១ នៅចំពោះមុខ អ.វ.ត.ក[20]។

១០. នៅថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានជម្រាបជូនអង្គជំនុំជម្រះថា ៥% នៃឯកសារដែលបានស្នើសុំឱ្យបកប្រែ មិនទាន់បកប្រែចប់ទេ គឺរហូតដល់ខែ មិថុនា ឆ្នាំ ២០១៣ ទើបចប់រួចរាល់[21]។

១១. នៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់បញ្ជីស្តាពរចំនួន ១៨៧ ទំព័រ បញ្ជាក់អំពីកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្ម ក្នុងពេលជំនុំជម្រះក្តី[22]។

១២. តាមរយៈចម្លើយតបនេះ ជាបឋម មេធាវីការពារក្តីលោក ខៀវ សំផន សូមគាំទ្រ និងឯកភាពលើមធ្យោបាយអង្គហេតុ និងអង្គច្បាប់ ដែលបានលើកឡើង នៅក្នុងចម្លើយតបជាបឋមរបស់មេធាវីការពារក្តីលោក នួន ជា។ លោក ខៀវ សំផន ទទួលយកសេចក្តីសន្និដ្ឋានរបស់លោក នួន ជា ពាក់ព័ន្ធនឹងច្បាប់គ្រប់គ្រងការទទួលយកកំណត់ហេតុស្តាប់ចម្លើយ អនុលោមតាមវិធាន ៩២ ស្ទួននៃវិធាននីតិវិធី និងភស្តុតាង នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី[23]។

១៣. សារណាជាលាយលក្ខណ៍អក្សរផ្សេងៗរបស់ភាគីនៃរឿងក្តី និងអនុស្សរណៈរបស់អង្គជំនុំជម្រះ

---

[20] សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានា នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E96/7 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២។

[21] សំណើរបស់សហព្រះរាជអាជ្ញាសុំបង្កើតនីតិវិធីពាក់ព័ន្ធនឹងការទទួលយកឯកសារ ដែលមិនបានបកប្រែគ្រប់ភាសាទាំងអស់របស់ អ.វ.ត.ក ឯកសារ E223/2/6 ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[22] ឧបសម្ព័ន្ធសម្ងាត់ទី ១៖ កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនបានកោះហៅឱ្យមកផ្តល់សក្ខីកម្ម ឯកសារ E223/2/7.2 ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣។

[23] ការឆ្លើយតបជាបឋមទៅនឹងសំណើបន្ថែមរបស់សហព្រះរាជអាជ្ញាសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងប្រតិចារឹក ឯកសារ E96/8/1 ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១២។

ស្តែងឱ្យឃើញថា យើងទាំងអស់គ្នាឯកភាពថា កំណត់ហេតុស្តាប់ចម្លើយប្រភេទខ្លះមិនអាចទទួលយកបានទេ ដោយសារតែមេធាវីការពារក្តីមិនមានលទ្ធភាពសួរដេញដោលម្ចាស់ចម្លើយ។ ក៏ប៉ុន្តែមេធាវីការពារក្តីលោក ខៀវ សំផន កត់សម្គាល់ឃើញថា ទ្រង់ទ្រាយនៃឯកសារប្រភេទនេះមិនមានឯកច្ឆន្ទភាពនោះទេ ហើយយើងខ្ញុំនឹងខិតខំពន្យល់អំពីទស្សនៈយល់ឃើញរបស់ខ្លួន នៅផ្នែកបន្ទាប់ខាងមុខនេះ។ ផ្នែកចុងក្រោយនៃចម្លើយតបនេះនឹងលើកឡើងអំពីការសង្កេតពាក់ព័ន្ធនឹងរបបនីតិវិធីដែលអនុវត្តចំពោះការទទួលយកជាភស្តុតាងនូវកំណត់ហេតុស្តាប់ចម្លើយ ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ និងតម្លៃជាភស្តុតាងដែលត្រូវផ្តល់ទៅឱ្យកំណត់ហេតុស្តាប់ចម្លើយទាំងនោះ។

## II- <u>ភាពមិនអាចទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយប្រភេទខ្លះ ដោយសារតែមេធាវីការពារក្តីមិនមានលទ្ធភាពសួរដេញដោល</u>

១៤. យោងតាមយុត្តិសាស្ត្រជាធរមាននៅចំពោះមុខតុលាការអន្តរជាតិផ្សេងទៀត និងដែលអាចយកមកអនុវត្តបាននៅក្នុងសំណុំរឿង ០០២/០១[24] ចម្លើយដែលអាចទទួលយកបាន ជំនួសឱ្យសក្ខីកម្មរបស់សាក្សីណាម្នាក់ ត្រូវបើកឱ្យមានការសួរដេញដោល ឬបើមិនដូច្នេះទេ ត្រូវច្រានចោល ប្រសិនបើចម្លើយនោះមានសារៈសំខាន់គ្រប់គ្រាន់ សម្រាប់ចោទប្រកាន់លើជនជាប់ចោទ។

១៥. ជាក់ស្តែង ភស្តុតាង នៅក្រោមគោលការណ៍នេះ ជាឯកសារពាក់ព័ន្ធនឹង៖ ក) ទង្វើឧក្រិដ្ឋរបស់ជនជាប់ចោទ ឬ ខ) បញ្ហាចម្រូងចម្រាស់ រវាងភាគីនៃរឿងក្តី។

១៦. ផ្ទុយទៅវិញ តាមទស្សនៈរបស់សហមេធាវីការពារក្តីលោក ខៀវ សំផន កំណត់ហេតុស្តាប់ចម្លើយមួយចំនួនធំ ដែលសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំដាក់ជាភស្តុតាង មានជាប់ពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលទៅនឹងទម្រង់នៃការទទួលខុសត្រូវ ដែលតាមរយៈនេះ សហព្រះរាជអាជ្ញាមានបំណងបង្ហាញការទទួលខុសត្រូវរបស់ជនជាប់ចោទ។

[24] សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានា នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E96/7 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២។

១៧. ទន្ទឹមនឹងនេះ សហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី ស្នើសុំឱ្យទទួលយកជាភ័ស្តុតាងនូវកំណត់ហេតុស្ដាប់ចម្លើយ ពាក់ព័ន្ធនឹងអង្គច្បាប់ ដែលជាបញ្ហាចម្រូងចម្រាស់ រវាងភាគីនៃរឿងក្ដី។ ជាដំបូង ភាគីបានស្នើដាក់កំណត់ហេតុស្ដាប់ចម្លើយ ដែលមានគោលដៅបង្ហាញអំពីល័ក្ខខ័ណ្ឌទូទៅ ដែលត្រូវបំពេញ ដើម្បីឱ្យឧក្រិដ្ឋកម្មចោទប្រកាន់ត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ បន្ទាប់មក ភាគីបានស្នើដាក់នូវកំណត់ហេតុស្ដាប់ចម្លើយ ដែលមានគោលដៅបង្ហាញថាមិនមានមូលដ្ឋានអនុញ្ញាតឱ្យជម្លៀសប្រជាជន តាមច្បាប់អន្តរជាតិ។ ដោយសារតែចំណុចទាំងពីរនេះជាបញ្ហា "ចម្រូងចម្រាស់" យោងតាមយុត្តិសាស្ត្រជាធរមាន មេធាវីការពារក្ដីសូមជំទាស់ទៅនឹងការដែលសហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី បង្ហាញភ័ស្តុតាងដាក់បន្ទុក ផ្អែកលើកំណត់ហេតុស្ដាប់ចម្លើយ ដោយមិនឱ្យមេធាវីការពារក្ដីសួរដេញដោលម្ចាស់ចម្លើយបាន។

## ក. __ភាពមិនអាចទទួលយកបាននៃកំណត់ហេតុស្ដាប់ចម្លើយ ដែលមានគោលដៅបង្ហាញអំពីភ័ស្តុតាងនៃធាតុផ្សំនៃទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ និងដីកាសន្និដ្ឋានស្ថាពរ__

១៨. ដូចអង្គជំនុំជម្រះបានរំឭកយ៉ាងត្រឹមត្រូវនៅក្នុងសេចក្ដីសម្រេច ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ ល័ក្ខខ័ណ្ឌចម្បងដែលគ្រប់គ្រងលើការទទួលយកកំណត់ហេតុស្ដាប់ចម្លើយ គឺថាកំណត់ហេតុស្ដាប់ចម្លើយប្រភេទនេះត្រូវពាក់ព័ន្ធនឹង *"ភ័ស្តុតាងនៃអង្គហេតុ ក្រៅពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ"*។

១៩. ដើម្បីកំណត់ថា តើកំណត់ហេតុស្ដាប់ចម្លើយណាមួយពាក់ព័ន្ធនឹងអង្គហេតុ ក្រៅពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ពុំគប្បីប្រកាន់យកវិធីសាស្ត្ររឹតត្បិត ដែលកម្រិតត្រឹមតែការច្រានចោលនូវកំណត់ហេតុស្ដាប់ចម្លើយ ដែលលើកឡើងអំពីអាកប្បកិរិយាតាមន័យចង្អៀតរបស់ជនជាប់ចោទណាម្នាក់នោះទេ។ ផ្ទុយទៅវិញ និងអនុលោមតាមយុត្តិសាស្ត្រជាធរមាន[25] យើងចាំបាច់ត្រូវផ្ដល់សារៈសំខាន់ដល់ការវិភាគមួយ ដែលគិតគូរទៅលើប្រភេទនៃអង្គហេតុដែលចោទប្រកាន់ទៅលើជន

---

[25] *រដ្ឋអាជ្ញា ទល់នឹង Milosević សេចក្ដីសម្រេចលើសំណើសុំរបស់រដ្ឋអាជ្ញាឱ្យទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សីអនុលោមតាមវិធាន ៩២ ស្ទួន* រឿងក្ដីលេខ IT-02-54-T ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៥ កថាខណ្ឌ ១៥។

ជាប់ចោទ និងទម្រង់នៃការចូលរួមទាំងមូល ដែលផ្អែកលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញាមានបំណងបង្ហាញពិរុទ្ធភាពរបស់ជនជាប់ចោទ។

២០. ជាក់ស្តែង វិធាន ៩២ ស្ទួន (ក) នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលអាចយកមកអនុវត្តបាន នៅក្នុងសំណុំរឿង ០០២/០១ នេះ មានគោលដៅច្រានចោលនូវរាល់កំណត់ហេតុស្តាប់ចម្លើយទាំងឡាយពាក់ព័ន្ធនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដែលផ្អែកលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញាមានបំណងបង្ហាញភ័ស្តុតាងថា៖ ១) ជនជាប់ចោទបានប្រព្រឹត្តដោយផ្ទាល់នូវឧក្រិដ្ឋកម្មចោទប្រកាន់ណាមួយ ២) ជនជាប់ចោទបានធ្វើផែនការ ញុះញង់ ឬបញ្ជាឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មចោទប្រកាន់ណាមួយ ៣) ជនជាប់ចោទបានជំរុញ ឬជួយអ្នកប្រព្រឹត្តឧក្រិដ្ឋកម្ម ដោយចូលរួមក្នុងការធ្វើផែនការ ការរៀបចំ ឬការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ ៤) ជនជាប់ចោទជាថ្នាក់លើរបស់ចារីដែលដល់ ឬជាចុងក្រោយ ៥) ជនជាប់ចោទបានដឹង ឬមានហេតុផលដឹងថាឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត[26]។

២១. សហព្រះរាជអាជ្ញាបានទទួលស្គាល់ថា ឯកសាររាប់រយ ដែលខ្លួនស្នើសុំដាក់ជាភ័ស្តុតាង មានធាតុផ្សំពាក់ព័ន្ធនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ។ ក៏ប៉ុន្តែ សហព្រះរាជអាជ្ញាបានអះអាងថាខ្លួនស្នើសុំដាក់ឯកសារចូលក្នុងសំណុំរឿង ដើម្បីបង្ហាញ *"គោលនយោបាយទូទៅ ឬរចនាសម្ព័ន្ធ"* មិនមែនបង្ហាញអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទនោះទេ[27]។ មេធាវីការពារក្តីយល់ឃើញថា ការបែងចែក រវាងរចនាសម្ព័ន្ធធ្វើសេចក្តីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជា នយោបាយរបស់បក្ស និងអំពើរបស់មេដឹកនាំបក្សនេះ មិនត្រឹមត្រូវនោះទេ។

២២. យោងតាមយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ពេលអយ្យការចោទប្រកាន់ថា ជនជាប់ចោទបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ត្រូវបានច្រានចោល

---

[26] *រដ្ឋអាជ្ញា ទល់នឹង Galić សេចក្តីសម្រេចលើបណ្តឹងសាទុក្ខតាមៗ ពាក់ព័ន្ធនឹងវិធាន ៩២ ស្ទួន (ក)* រឿងក្តីលេខ IT-98-29-AR73.2 ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០២ កថាខណ្ឌ ១០។

[27] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន ស្នើសុំកែសម្រួលបញ្ជីភ័ស្តុតាងជាក់លាក់ ឯកសារ E223/1 កថាខណ្ឌ ១២។

ផ្អែកតាមវិធាន ៩២ ស្ទួន នូវកំណត់ហេតុស្តាប់ចម្លើយដែលមានគោលដៅបង្ហាញថា៖ ១) ជនជាប់ចោទបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម និង ២) ជនជាប់ចោទបានចែករំលែកជាមួយចារីដែលដល់នូវធាតុផ្សំអត្តនោម័តិ ដែលជាល័ក្ខខ័ណ្ឌចាំបាច់ សម្រាប់បង្ហាញពីការទទួលខុសត្រូវព្រហ្មទណ្ឌ[28]។ ជាក់ស្តែង គោលការណ៍ច្រានចោលកំណត់ហេតុស្តាប់ចម្លើយ ពាក់ព័ន្ធនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ មិនមែនសំដៅត្រឹមតែធាតុផ្សំសត្យានុម័តិនៃទម្រង់នៃការទទួលខុសត្រូវនោះទេ គឺសំដៅដល់ធាតុផ្សំអត្តនោម័តិផ្ទាល់នៃទម្រង់នេះផងដែរ។ ដូចគ្នានេះដែរ "អាកប្បកិរិយា" របស់ជនជាប់ចោទ ក៏រួមបញ្ចូលទាំងការខកខានមិនបានបំពេញកាតព្វកិច្ចចាត់វិធានការផងដែរ[29]។

២៣. ក៏ប៉ុន្តែ សហមេធាវីការពារក្តីលោក ខៀវ សំផន ធ្លាប់បានគូសបញ្ជាក់នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន នៅក្នុងសំណុំរឿង ០០២/០១ រួចមកហើយថា សហចៅក្រមស៊ើបអង្កេត នៅក្នុងដីកាដំណោះស្រាយ និងសហព្រះរាជអាជ្ញា នៅក្នុងដីកាសន្និដ្ឋានស្ថាពរ មានគោលដៅបង្ហាញរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល ជាសហឧក្រិដ្ឋកម្មរួមយ៉ាងទូលំទូលាយ[30]។

២៤. ជាក់ស្តែង ដោយសារតែមេធាវីការពារក្តីទទួលស្គាល់ថា លោក ខៀវ សំផន បានចូលរួមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងឋានៈជាប្រធានគណៈប្រធានរដ្ឋ និងជាសមាជិកត្រៀមគណៈមជ្ឈិម សហព្រះរាជអាជ្ញាមានបន្ទុកផ្តល់ភ័ស្តុតាងបង្ហាញអំពីអត្ថិភាពនៃគោលនយោបាយឧក្រិដ្ឋ ដែលត្រូវបានបង្កើត និងរៀបចំដារចនាសម្ព័ន្ធដោយរដ្ឋាភិបាលនេះ ក៏ដូចជាការចូលរួមយ៉ាងសកម្មរបស់ជនជាប់ចោទក្នុងគោលនយោបាយនីមួយៗ ជាជាងបង្ហាញពីការចូលរួមរបស់ជនជាប់ចោទ ក្នុងរបប

---

[28] សូមមើល *រដ្ឋអាជ្ញា ទល់នឹង Galić សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ ពាក់ព័ន្ធនឹងវិធាន ៩២ ស្ទួន (គ)* រឿងក្តីលេខ IT-98-29-AR73.2 ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០២ កថាខណ្ឌ ១០។ សូមមើលផងដែរ៖ *រដ្ឋអាជ្ញា ទល់នឹង Tadić រឿងក្តីលេខ* IT-94-1-1 ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ២២០។

[29] សូមមើល *រដ្ឋអាជ្ញា ទល់នឹង Galić សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ ពាក់ព័ន្ធនឹងវិធាន ៩២ ស្ទួន (គ)* រឿងក្តីលេខ IT-98-29-AR73.2 ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០២ កថាខណ្ឌ ១១។

[30] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន នៅក្នុងសំណុំរឿង ០០២/០១របស់មេធាវីការពារក្តីលោក ខៀវ សំផន ឯកសារ E163/5/9 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៤៣ និងកថាខណ្ឌបន្តបន្ទាប់។

កម្ពុជាប្រជាធិបតេយ្យ[31]។

២៥. ហេតុដូច្នេះ ដូចបានគូសបញ្ជាក់យ៉ាងត្រឹមត្រូវដោយមេធាវីការពារក្តីលោក នួន ជា៖ *"លក្ខណៈនៃឋានានុក្រមដែលបានភ្ជាប់ជនជាប់ចោទ ទៅនឹងចារីដែលដល់នៃឧក្រិដ្ឋកម្មចោទប្រកាន់ គឺពិតជាមានសារៈសំខាន់បំផុត ហើយជាបញ្ហាចម្រូងចម្រាស់ នៅក្នុងសំណុំរឿង ០០២/០១។ សក្ខីកម្មពាក់ព័ន្ធនឹងឋានានុក្រមនេះ ត្រូវតែសួរដេញដោល ជាពិសេស នៅពេលសក្ខីកម្មនោះចេញមកពីកម្មាភិបាលថ្នាក់ទាប ដែលមានចេតនាច្បាស់ក្រឡែតក្នុងការទម្លាក់ការទទួលខុសត្រូវឲ្យថ្នាក់លើ ហើយចាត់ទុកខ្លួនឯងគ្រាន់តែជាកូនអុកគ្មានឆន្ទៈ គ្មានអំណាច ក្នុងកណ្តាប់ដៃរបបនោះ"*[32]។

២៦. អាស្រ័យហេតុនេះ មេធាវីការពារក្តីលោក ខៀវ សំផន សូមគាំទ្រមេធាវីការពារក្តីលោក នួន ជា ដែលយល់ឃើញថា សក្ខីកម្មពាក់ព័ន្ធនឹង៖ ១) រចនាសម្ព័ន្ធរដ្ឋបាល ២) ប្រព័ន្ធទំនាក់ទំនងការងារ និង ៣) កំណត់ហេតុស្តាប់ចម្លើយ ដែលលើកឡើងអំពីអ្វីដែលដឹកាដំណោះស្រាយហៅជាទូទៅថា "មជ្ឈិម" (ពាក្យនេះសំដៅដល់គ្រប់អង្គភាពធ្វើសេចក្តីសម្រេចទាំងអស់ របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ) មិនអាចទទួលយកបានទេ ប្រសិនបើមិនផ្តល់ឱកាសដល់មេធាវីការពារក្តីក្នុងការជំទាស់ទៅនឹងកំណត់ហេតុស្តាប់ចម្លើយទាំងនោះ។ បើមិនដូច្នេះទេ នេះគឺជាការរំលោភយ៉ាងច្បាស់ក្រឡែតទៅលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌។

## ខ. ភាពមិនអាចទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយ ដែលដាក់ដើម្បីបង្ហាញអំពីអត្ថិភាពនៃ "ការវាយប្រហារជាទូទៅ និងជាលក្ខណៈប្រព័ន្ធ" ទៅលើប្រជាជនស៊ីវិល

### ១. ភាពមិនអាចទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយ ដែលដាក់ដើម្បីបង្ហាញអំពីអត្ថិភាពនៃគោលនយោបាយរដ្ឋដែលមានគោលដៅរើសអើង ស្មើនឹងការ "វាយប្រហារ"

[31] ដូចយោងខាងលើ។

[32] ការឆ្លើយតបជាបឋមទៅនឹងសំណើបន្ថែមរបស់សហព្រះរាជអាជ្ញាសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងប្រតិចារឹក ឯកសារ E96/8/1 ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ កថាខណ្ឌ ៣៤។

២៧. លោក ខៀវ សំផន ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាអំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ)។ មាត្រា ៥ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ចែងថា បទល្មើសជាក់លាក់ទាំងនេះ គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រសិនបើត្រូវបានប្រព្រឹត្ត *"ក្នុងក្របខ័ណ្ឌនៃការវាយប្រហារជាទូទៅ ឬដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិល ដោយមូលហេតុជាតិនយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ណាមួយ"*។

២៨. រាល់និយមន័យទាំងអស់ពាក់ព័ន្ធនឹងលក្ខខ័ណ្ឌទូទៅដែលត្រូវបំពេញ ដើម្បីឱ្យឧក្រិដ្ឋមួយត្រូវបានចាត់ទុកថាជាឧក្រិដ្ឋប្រឆាំងមនុស្សជាតិ កំណត់ថា ការវាយប្រហារត្រូវ៖ ក) មានលក្ខណៈទូទៅ ឬដោយមានការរៀបចំ និង ខ) ប្រឆាំងទៅលើប្រជាជនស៊ីវិល។ ផ្ទុយទៅវិញ មិនមានការឯកភាពជាឯកច្ឆន្ទចំពោះបរិបទនៃការវាយប្រហារនោះទេ[33]។

២៩. ចំពោះតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ការវាយប្រហារត្រូវប្រព្រឹត្តក្នុងក្របខ័ណ្ឌនៃជម្លោះប្រដាប់អាវុធ។ ផ្ទុយទៅវិញ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វាន់ដា តម្រូវឱ្យការវាយប្រហារត្រូវធ្វើឡើង ក្នុងលក្ខណៈរើសអើង គឺដោយមូលហេតុជាតិនយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា[34]។

៣០. មាត្រា៥ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ឯកភាពតាមនិយមន័យនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វាន់ដា ដោយកំណត់ថាការវាយប្រហារត្រូវធ្វើឡើង ក្នុងលក្ខណៈរើសអើង។ អាស្រ័យហេតុនេះ ដូចមេធាវីការពារក្ដីលោក ខៀវ សំផន បានលើកឡើងនៅក្នុងសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន សហព្រះរាជអាជ្ញាត្រូវបង្ហាញថា៖ ក)

[33] សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន នៅក្នុងសំណុំរឿង ០០២/០១របស់មេធាវីការពារក្ដីលោក ខៀវ សំផន ឯកសារ E163/5/9 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣។

[34] ដូចយោងខាងលើ។

ឧក្រិដ្ឋកម្មចោទប្រកាន់ត្រូវបានប្រព្រឹត្ត[35] ខ) ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃការវាយប្រហារ គ) ការវាយប្រហារមានលក្ខណៈជាទូទៅ ឬជាប្រព័ន្ធ ឃ) ធ្វើឡើងប្រឆាំងនឹងប្រជាជនស៊ីវិល ង) ដោយមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ច) ជាការអនុវត្ត ឬ បន្តនយោបាយរបស់រដ្ឋ ឬអង្គការចាត់តាំងណាមួយ ដែលមានគោលដៅវាយប្រហារបែបនេះ[36]។

៣១. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាបានលើកឡើងថា៖ *"ជារួម កំណត់ហេតុស្តាប់ចម្លើយសាក្សីបានផ្តល់នូវភ័ស្តុតាងមានតម្លៃ សម្រាប់បង្ហាញនូវការចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ជាពិសេស កំណត់ហេតុស្តាប់ចម្លើយសាក្សីបានផ្តល់ភ័ស្តុតាងអំពី៖ ទំហំនៃការជម្លៀសប្រជាជនជាធាតុផ្សំពាក់ព័ន្ធ សម្រាប់បង្ហាញអត្ថិភាពនៃការវាយប្រហារជាទូទៅ ឬជាលក្ខណៈប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិល ដែលជាល័ក្ខខ័ណ្ឌទូទៅដែលត្រូវបំពេញដើម្បីឲ្យអំពើចោទប្រកាន់អាចត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ [...] ច) លក្ខណៈនៃការជម្លៀសដែលត្រូវបានធ្វើផែនការនិងរៀបចំយ៉ាងល្អ ជាធាតុផ្សំពាក់ព័ន្ធ សម្រាប់បង្ហាញថា មិនមានមូលដ្ឋានអនុញ្ញាតឲ្យជម្លៀសប្រជាជន តាមច្បាប់អន្តរជាតិ [...] ឆ) ការរើសអើងជនរងគ្រោះ ផ្អែកលើចរិតលក្ខណៈបុគ្គល រួមទាំងសមាជិកភាពនៅក្នុងក្រុមគោលដៅ ដូចជា ប្រជាជនថ្មី អ្នកជាប់ទាក់ទងនឹងរបប លន់ នល់ ជនជាតិភាគតិចចាម ចិន និងខ្មែរកម្ពុជាក្រោម ជាធាតុផ្សំពាក់ព័ន្ធ ដើម្បីបំពេញតាមល័ក្ខខ័ណ្ឌតម្រូវនៃមូលដ្ឋាននៃការរើងអើង ដែលជាល័ក្ខខ័ណ្ឌទូទៅដែលត្រូវបំពេញដើម្បីឲ្យអំពើចោទប្រកាន់អាចត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងដើម្បីបង្ហាញអំពីធាតុផ្សំមួយចំនួនចំពោះឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស"*។

---

[35] ឧទាហរណ៍ អំពីមនុស្សឃាត សូមមើល៖ *រដ្ឋអាជ្ញា ទល់នឹង Milan Milutinović និងអ្នកផ្សេងទៀត* រឿងក្តីលេខ IT-05-87-T សាលក្រម ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ ("សាលក្រម Milutinović")។ នៅក្នុងសាលក្រមនេះ អង្គជំនុំជម្រះបញ្ជាក់ថា៖ *"ដើម្បីបង្ហាញថា អំពើមនុស្សឃាតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្ត រដ្ឋអាជ្ញាត្រូវបង្ហាញអំពី (ក) ធាតុផ្សំសត្យានុម័តិ និងធាតុផ្សំអត្តនោម័តិ នៃអំពើមនុស្សឃាត និង (ខ) ល័ក្ខខ័ណ្ឌតម្រូវទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"* កថាខណ្ឌ ១៧៣។

[36] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាននៅក្នុងសំណុំរឿង ០០២/០១ របស់មេធាវីការពារក្តីលោក ខៀវ សំផន ឯកសារ E163/5/9 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ១៣ និងកថាខណ្ឌបន្តបន្ទាប់។

៣២. ច្បាស់ណាស់ថា នេះគឺជាបញ្ហាស្នូល នៅក្នុងសំណុំរឿង ០០២/០១។ មេធាវីការពារក្ដីលោក ខៀវ សំផន យល់ឃើញថា យោងតាមយុត្តិសាស្ត្រជាធរមាន នេះគឺជាបញ្ហា "ចម្រូងចម្រាស់" រវាងភាគីនៃរឿងក្ដី។ ជាក់ស្ដែង ដើមបណ្ដឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា មានបំណងបង្ហាញអំពីអត្ថិភាពនៃគោលនយោបាយរើសអើង ដែលបំពេញល័ក្ខខ័ណ្ឌទូទៅ ដើម្បីឱ្យឧក្រិដ្ឋកម្មចោទប្រកាន់ត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ក៏ប៉ុន្តែ នៅដំណាក់កាលនេះនៃការជំនុំជម្រះក្ដី បញ្ហានេះមិនងាយដោះស្រាយនោះទេ ហើយជាស្នូលនៃការពិភាក្សាដេញដោលរវាងភាគី។

៣៣. ជាក់ស្ដែង កំណត់ហេតុស្ដាប់ចម្លើយ ពាក់ព័ន្ធនឹងធាតុផ្សំ "ទូទៅ" មិនអាចទទួលយកជាស្វ័យប្រវត្តិបើគ្មានការសួរដេញដោលទេ។ កំណត់ហេតុស្ដាប់ចម្លើយប្រភេទនេះអាចត្រូវបានអង្គជំនុំជម្រះប្រកាសទទួលយក ទាល់តែល័ក្ខខ័ណ្ឌដែលត្រូវបំពេញដើម្បីឱ្យឧក្រិដ្ឋកម្មចោទប្រកាន់ត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានបើកឱ្យមានការពិភាក្សាដេញដោលរួចហើយរវាងភាគី និងគ្រាន់តែជា "បញ្ហាបន្ទាប់បន្សំ" យោងតាមយុត្តិសាស្ត្រជាធរមាន[37]។

៣៤. ផ្ទុយទៅវិញ នៅក្នុងសេចក្ដីសម្រេច ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានចង្អុលបង្ហាញថាអាចដាក់ឱ្យពិភាក្សាដេញដោលបាននូវកំណត់ហេតុស្ដាប់ចម្លើយ ឬប្រតិចារឹក ប្រសិនបើភ័ស្តុតាងក្រោមទម្រង់នេះ៖ *"[...] ទាក់ទងនឹងបរិបទប្រវត្តិសាស្ត្រ នយោបាយ ឬយោធា នៃសំណុំរឿង លើកឡើងអំពីអង្គហេតុជាក់លាក់នៃឧក្រិដ្ឋកម្មចោទប្រកាន់ ឬល័ក្ខខ័ណ្ឌទូទៅដែលត្រូវបំពេញដើម្បីឱ្យអំពើចោទប្រកាន់ត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មតាមច្បាប់អន្តរជាតិ [...]"*។

៣៥. អាស្រ័យហេតុដូចបានរៀបរាប់ខាងលើនេះ សហមេធាវីការពារក្ដីលោក ខៀវ សំផន យល់ឃើញ

---

[37] *រដ្ឋអាជ្ញា ទល់នឹង Naletilić និង Martinović* រឿងក្ដីលេខ IT-98-34-PT សេចក្ដីសម្រេចលើការជូនដំណឹងរបស់រដ្ឋអាជ្ញាអំពីចេតនាក្នុងការបង្ហាញកំណត់ហេតុសវនាការ យោងតាមវិធាន ៩២ ស្ទួន (ឃ) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០១ កថាខណ្ឌ ១២។ នៅក្នុងរឿងក្ដីនេះ ដូចមេធាវីការពារក្ដីលោក នួន ជា បានគូសបញ្ជាក់ អង្គជំនុំជម្រះបានទទួលយកភ័ស្តុតាងដែលសំដៅបង្ហាញអំពីអត្ថិភាពនៃការវាយប្រហារជាទូទៅ និងជាលក្ខណៈប្រព័ន្ធ ក៏ព្រោះតែបញ្ហានេះត្រូវបានពិភាក្សាយ៉ាងទូលំទូលាយរួចហើយនៅចំពោះមុខអង្គជំនុំជម្រះ ហើយសាក្សីពាក់ព័ន្ធក៏ត្រូវបានសួរដេញដោលរួចហើយដែរ នៅក្នុងការជំនុំជម្រះក្ដីផ្សេងទៀត។ កំណត់ហេតុស្ដាប់ចម្លើយដែលមានភ័ស្តុតាងប្រហាក់ប្រហែលត្រូវបានច្រានចោល ដោយសារតែគ្មានការសួរដេញដោល នៅក្នុងរឿងក្ដីផ្សេងទៀត។

ថាអង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ហើយសូមជំទាស់ទៅនឹងការទទួលយកជាភ័ស្តុតាងនូវកំណត់ហេតុស្តាប់ចម្លើយដែលមានគោលដៅបង្ហាញអំពីអង្គហេតុប្រភេទនេះ។ ការមិនស្តាប់ចម្លើយសាក្សី ដែលលើកឡើងអំពីបញ្ហាស្នូលទាំងនេះរបស់សហព្រះរាជអាជ្ញា ជាការរំលោភសិទ្ធិរបស់មេធាវីការពារក្តី។

៣៦. ម្យ៉ាងវិញទៀត សហព្រះរាជអាជ្ញាបានលើកឡើងថា កំណត់ហេតុស្តាប់ចម្លើយ ដែលត្រូវបានស្នើសុំដាក់ ជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ គឺជាភ័ស្តុតាង *"មានភាពពាក់ព័ន្ធ សម្រាប់បង្ហាញថាមិនមានមូលដ្ឋានអនុញ្ញាតឲ្យជម្លៀសប្រជាជន តាមច្បាប់អន្តរជាតិ"*[38]។

៣៧. មេធាវីការពារក្តីលោក ខៀវ សំផន យល់ឃើញថា កំណត់ហេតុស្តាប់ចម្លើយប្រភេទនេះមិនគប្បីទទួលយកជាភ័ស្តុតាង ដោយមិនកោះហៅម្ចាស់ចម្លើយឲ្យភាគីសួរដេញដោលនោះទេ។ នេះគឺជាបញ្ហាវិវាទរវាងភាគីនៃរឿងក្តី ហើយនឹងបង្កឲ្យមានព្យសនកម្មយ៉ាងធ្ងន់ធ្ងរដល់សហជនជាប់ចោទប្រសិនបើសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ទទួលបានសិទ្ធិក្នុងការបង្ហាញភ័ស្តុតាងដាក់បន្ទុក តាមរយៈតែការប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយ ជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់។

## ២. ភាពមិនអាចទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយ ដែលដាក់ដើម្បីបង្ហាញអំពីការដឹងពីការ "វាយប្រហារ" ទៅលើប្រជាជនស៊ីវិល និងមូលដ្ឋាននៃការរើសអើង

៣៨. នៅក្នុងសាលក្រម ឌុច អង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើយុត្តិសាស្ត្រ *Kunarac* ដើម្បីកំណត់ធាតុផ្សំអត្តនោម័តិនៃការវាយប្រហារ[39]។ អង្គជំនុំជម្រះបានបញ្ជាក់យ៉ាងដូច្នេះថា៖ *"អំពើរបស់ជនជាប់ចោទត្រូវតែជាផ្នែកមួយនៃការវាយប្រហារជាសត្យានុម័ត ទោះជាអំពើនោះជាអំពើប្រភេទណា ឬមានផលវិបាកយ៉ាងណាក៏ដោយ ដរាបណាអំពើទាំងនោះមិនត្រូវបានកាត់ផ្តាច់ទាំងស្រុង*

---

[38] សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឲ្យទទួលយកចម្លើយសាក្សីពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន នៅដំណាក់ទី ១ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារ E208 កថាខណ្ឌ ១៥។

[39] សាលក្រមលើរឿងក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច ឯកសារ E188 ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ("សាលក្រម ឌុច") កថាខណ្ឌ ៣១៨-៣១៩។

*ចេញពីបរិបទនៃការវាយប្រហារ"*[40]។ ប៉ុន្តែ នៅក្នុងរឿងក្តីទាំងពីរ *Kunarac* និង ឌុច ជនជាប់ចោទជាចារីផ្ទាល់នៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់។

៣៩. ដូច្នេះ ក្នុងសាលក្រមនៃសំណុំរឿងយើងនេះ អង្គជំនុំជម្រះនឹងជួបបញ្ហាក្នុងការកំណត់អំពីលក្ខណៈវិនិច្ឆ័យដែលអាចឱ្យភ្ជាប់ទំនាក់ទំនងជាយថាហេតុ រវាងជនជាប់ចោទ និងឧក្រិដ្ឋកម្មចោទប្រកាន់។ យុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា បានខកខានតាំងពីយូរយារណាស់មកហើយ ក្នុងការបែងចែកឱ្យច្បាស់រវាងធាតុផ្សំអត្តនោម័តិចំពោះជនជាប់ចោទ និងធាតុផ្សំអត្តនោម័តិចំពោះចារីដែលដល់នៃឧក្រិដ្ឋកម្ម។ កង្វះខាតនេះត្រូវបានរិះគន់ដោយឯកសារវិភាគច្បាប់នានា[41] ហើយត្រូវបានកែតម្រូវដោយយុត្តិសាស្ត្រនៅក្នុងសាលក្រម *Milutinović*[42]។ នៅក្នុងរឿងក្តី *Milutinović* តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានបញ្ជាក់ថា ដើម្បីបង្កើតឱ្យមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវមានធាតុផ្សំដូចតទៅ៖ ១) អំពើរបស់ចារីដែលដល់នៃឧក្រិដ្ឋកម្មស្ថិតនៅក្នុងបរិបទនៃការវាយប្រហារ[43] និង ២) ជនជាប់ចោទដឹងឮអំពីការវាយប្រហារ ទោះជាខ្លួនជាចារីដែលដល់ ឬមិនមែនក៏ដោយ[44]។

៤០. នៅក្នុងសំណើរបស់ខ្លួន ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាលើកឡើងថា៖ *"សម្រង់នៅក្នុងឧបសម្ព័ន្ធ I និងឧបសម្ព័ន្ធ II ដែលយកចេញមកពីចម្លើយសាក្សីមួយចំនួន មានភ័ស្តុតាងទាក់ទងនឹងអំពើ និងការអាកប្បកិរិយារបស់ជនជាប់ចោទម្នាក់ ឬច្រើននាក់។ ក៏ប៉ុន្តែ សូមគូសបញ្ជាក់ថា ទោះតាមវិធីណាក៏ដោយ ភ័ស្តុតាងនេះមិនទាក់ទងនឹងការដឹងឮរបស់ជនជាប់ចោទអំពីការជម្លៀសប្រជាជន ឬការចូលរួមរបស់ជនជាប់ចោទក្នុងការការរៀបចំ នោះទេ"*[45]។

---

[40] សាលក្រម ឌុច កថាខណ្ឌ ៣១៨។

[41] ឧទាហរណ៍ សូមមើល Boas, Bischoff និង Reid, *International Criminal Law Practioner Library ភាគ II- ធាតុផ្សំនៃឧក្រិដ្ឋកម្ម តាមច្បាប់អន្តរជាតិ* គ្រឹះស្ថានបោះពុម្ពផ្សាយ Cambridge University Press (ឆ្នាំ ២០០១) ទំព័រ ៣៥-៤១។

[42] សាលក្រម *Milutinović* កថាខណ្ឌ ១៥៣ ដល់កថាខណ្ឌ ១៦២។

[43] ដូចយោងខាងលើ កថាខណ្ឌ ១៥២។

[44] ដូចយោងខាងលើ កថាខណ្ឌ ១៥៣ ដល់កថាខណ្ឌ ១៥៦។

[45] សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឱ្យទទួលយកចម្លើយសាក្សីពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន នៅដំណាក់ទី ១ ចុះថ្ងៃ

៤១. ម្យ៉ាងទៀត សហព្រះរាជអាជ្ញាគូសបញ្ជាក់ថា សម្រង់ចម្លើយសាក្សីផ្ដល់នូវភស្តុតាងស៊ីសង្វាក់គ្នា សំដៅបង្ហាញឱ្យឃើញ៖ *[...] (ឃ) ការរើសអើងទៅលើប្រជាជន ១៧ មេសា នៅពេលធ្វើដំណើរទៅដល់ទីតាំងថ្មី ជាធាតុផ្សំពាក់ព័ន្ធ ដើម្បីបំពេញតាមល័ក្ខខ័ណ្ឌតម្រូវនៃ**មូលដ្ឋាននៃការរើសអើង** ដែលជាល័ក្ខខ័ណ្ឌទូទៅដែលត្រូវបំពេញ ដើម្បីឱ្យអំពើចោទប្រកាន់អាចត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ [...]"*[46]។

៤២. លើសពីនេះទៀត សហព្រះរាជអាជ្ញាមិនបានបញ្ជាក់ទេថា តើត្រូវបង្ហាញឱ្យឃើញមូលដ្ឋាននៃការរើសអើងរបស់ចារីដែលដល់នៃឧក្រិដ្ឋកម្ម ឬមូលដ្ឋាននៃការរើសអើងរបស់ជនជាប់ចោទ។ ដូច្នេះ ការបែងចែកពិបាកនឹងធ្វើណាស់។ ម្យ៉ាងវិញទៀត នៅពេលពិនិត្យមើលរួមគ្នាជាមួយនឹងកំណត់ហេតុស្តាប់ចម្លើយពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារ ច្បាស់ណាស់ថាមូលដ្ឋាននៃការរើសអើងដែលសហព្រះរាជអាជ្ញាព្យាយាមបង្ហាញឱ្យឃើញ តាមរយៈកំណត់ហេតុស្តាប់ចម្លើយទាំងនេះ ត្រូវតែមានទំនាក់ទំនងជាមួយធាតុផ្សំអត្តនោម័ត ដែលសហព្រះរាជអាជ្ញាមានបំណងបង្ហាញ ចំពោះសហជនជាប់ចោទ។

៤៣. ត្រង់ចំណុចនេះ មេធាវីការពារក្ដីលោក ខៀវ សំផន ជំទាស់ទៅនឹងការដែលសហព្រះរាជអាជ្ញាផ្អែកលើកំណត់ហេតុស្តាប់ចម្លើយ ដើម្បីបង្ហាញអត្ថិភាពនៃធាតុផ្សំអត្តនោម័ត ដែលចាំបាច់ក្នុងការបង្កើតលក្ខណៈវិនិច្ឆ័យ ដែលអាចឱ្យចាត់ទុកឧក្រិដ្ឋកម្មចោទប្រកាន់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ជាងនេះទៅទៀត មេធាវីការពារក្ដីនឹងទទួលរងនូវព្យសនកម្មធ្ងន់ធ្ងរ ប្រសិនបើខ្លួនមិនទទួលបានឱកាសក្នុងការសួរដេញដោលម្ចាស់ចម្លើយ ដែលនិយាយអំពីអង្គច្បាប់ស្នូល នៅក្នុងក្របខ័ណ្ឌនៃសំណុំរឿង ០០២/០១។ នេះគឺជាការរំលោភសិទ្ធិជាសារវ័ន្តរបស់មេធាវីការពារក្ដី ដែលមានវិសមិតភាពជាមួយនឹងកិច្ចដំណើរការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌។

## III- <u>ការសង្កេតលើនិដ្ឋភាពនីតិវិធី ដែលគ្រប់គ្រងការដាក់ឱ្យពិភាក្សាដេញដោលនូវកំណត់</u>

---

ទី ១៥ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារ E208 កថាខណ្ឌ ១០។

[46] ដូចយោងខាងលើ កថាខណ្ឌ ១៥។

## <u>ហេតុស្តាប់ចម្លើយ ដែលសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី បានស្នើ និងតម្លៃជាភស្តុតាងនៃកំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងនេះ</u>

### ក. <u>កាតព្វកិច្ចរបស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការញែកផ្នែកអាចទទួលយកបាន ចេញពីផ្នែកមិនអាចទទួលយកបាន នៅក្នុងកំណត់ហេតុស្តាប់ចម្លើយដែលបានស្នើដាក់ឱ្យពិភាក្សាដេញដោល</u>

៤៤. ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ នៅក្នុងចម្លើយតបបឋមរបស់ខ្លួន មេធាវីការពារក្តីលោក នួន ជា បានលើកឡើងថា ប្រសិនបើផ្នែកខ្លះនៃកំណត់ហេតុស្តាប់ចម្លើយសាក្សីម្នាក់ ដែលនឹងមិនមកផ្តល់នៅក្នុងសវនាការ មិនអាចទទួលបានទេ មានតែផ្នែកអាចទទួលយកបានប៉ុណ្ណោះ ទើបអាចយកមកដាក់នៅចំពោះមុខអង្គជំនុំជម្រះបាន។ ជាក់ស្តែង ដូចលោក នួន ជា បានគូសបញ្ជាក់រួចមកហើយ ភាគីស្នើសុំដាក់កំណត់ហេតុស្តាប់ចម្លើយសាក្សី មានកាតព្វកិច្ចចង្អុលបង្ហាញថាតើផ្នែកណាខ្លះអាចទទួលយកបាន[47]។

៤៥. មេធាវីការពារក្តីលោក ខៀវ សំផន គាំទ្រការវិភាគនេះ និងស្នើសុំអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ចង្អុលបង្ហាញឱ្យបានច្បាស់ និងអនុលោមតាមច្បាប់ដែលអនុវត្តចំពោះការទទួលយកជាភស្តុតាងនូវកំណត់ហេតុស្តាប់ចម្លើយ ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ដែលបានលើកឡើងខាងលើ ថាតើផ្នែកណាខ្លះនៃកំណត់ហេតុស្តាប់ចម្លើយដែលខ្លួនមានបំណងប្រើប្រាស់ ។

៤៦. ប្រសិនបើគ្មានការចង្អុលបង្ហាញអំពីផ្នែកអាចទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយទេ កំណត់ហេតុស្តាប់ចម្លើយនោះត្រូវច្រានចោលទាំងស្រុង។ អាស្រ័យហេតុនេះ ចំពោះកំណត់ហេតុស្តាប់

---

47 ការឆ្លើយតបជាបឋមទៅនឹងសំណើបន្ថែមរបស់សហព្រះរាជអាជ្ញាសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងប្រតិចារឹក ឯកសារ E96/8/1 ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ កថាខណ្ឌ ១៥ និង កថាខណ្ឌ ១៦ ដកស្រង់ជាអាទិ៍ *រដ្ឋអាជ្ញា ទល់នឹង* Bagosora *សេចក្តីសម្រេចលើការទទួលកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលទទួលមរណភាព* ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៥ កថាខណ្ឌ ១៧។

ចម្លើយទាំងអស់ដែលមានផ្អែកមិនអាចទទួលយកបាន មេធាវីការពារក្តីលោក ខៀវ សំផន ស្នើសុំកោះហៅម្ចាស់ចម្លើយឱ្យមកបង្ហាញខ្លួនដើម្បីសួរដេញដោល ឬបើមិនដូច្នោះទេ យើងខ្ញុំសូមជំទាស់ទៅនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយទាំងនោះជាភស្តុតាង។

## ខ. ភាតព្វកិច្ចរបស់អង្គជំនុំជម្រះ ក្នុងការទទួលយកកំណត់ហេតុស្តាប់ចម្លើយតែក្នុងចំនួន "សមស្រប" ប៉ុណ្ណោះ

៤៧. នៅក្នុងសេចក្តីសម្រេច ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានកំណត់អំពីលក្ខណៈវិនិច្ឆ័យទទួលយកជាភស្តុតាងនូវកំណត់ហេតុស្តាប់ចម្លើយ ឬប្រតិចារឹក[48]។ លោក ខៀវ សំផន យល់ឃើញថា សហព្រះរាជអាជ្ញាមិនគោរពតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះនោះទេ។

៤៨. ដូចមេធាវីការពារក្តីលោក ខៀវ សំផន បានគូសបញ្ជាក់រួចហើយនៅក្នុងសារណាមុនៗរបស់ខ្លួន[49] កំណត់ហេតុស្តាប់ចម្លើយ ក្នុងឧបសម្ព័ន្ធ ១០ ដល់ ១៦ នៃសំណើបន្ថែមរបស់សហព្រះរាជអាជ្ញា[50] ពាក់ព័ន្ធនឹងប្រធានបទក្រៅអង្គហេតុនៃសំណុំរឿង ០០២/០១។ ហេតុដូច្នេះ មេធាវីការពារលោក ខៀវ សំផន យល់ឃើញថា កំណត់ហេតុស្តាប់ចម្លើយ ក្នុងឧបសម្ព័ន្ធ ១០ ដល់ ១៦ មិនមានភាពពាក់ព័ន្ធ ហើយចូលក្នុងលក្ខណៈវិនិច្ឆ័យបដិសេធភស្តុតាង ដូចមានចែងក្នុងវិធាន ៨៧(៣)(ក)។

៤៩. ម្យ៉ាងទៀត មេធាវីការពារក្តីលោក ខៀវ សំផន សូមរំឭកដល់អង្គជំនុំជម្រះថា អង្គជំនុំជម្រះមានអំណាចឆន្ទានុសិទ្ធិក្នុងការទទួលយកឯកសារធ្វើជាភស្តុតាង ប៉ុន្តែ អំណាចនេះត្រូវតែអនុវត្តឱ្យ

---

48 សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានា នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E96/7 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ២៤។

49 មតិគាំទ្រសំណើរបស់លោក អៀង សារី E221 និងស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូងឱ្យបង្គាប់ដល់សហព្រះរាជអាជ្ញាធ្វើការកែតម្រូវបញ្ជីសក្ខីកម្មជាលាយលក្ខណ៍អក្សរ ដែលសហព្រះរាជអាជ្ញាមានបំណងដាក់បញ្ចូលក្នុងការពិភាក្សាដេញដោលជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ ឯកសារ E223 ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២។

50 សំណើបន្ថែមរបស់សហព្រះរាជអាជ្ញាដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងប្រតិចារឹក ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ពី ១-១៦ ឯកសារ E96/8 ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២។

ស្របតាម "ផលប្រយោជន៍យុត្តិធម៌" ជានិច្ច។ សញ្ញាណ "ផលប្រយោជន៍យុត្តិធម៌" រួមមានកាតព្វកិច្ចរបស់អង្គជំនុំជម្រះ ក្នុងការរក្សាទុកចំនួនសមស្របនៃភស្តុតាងដែលបានដាក់ក្នុងសំណុំរឿង[51]។ ក្នុងន័យនេះ សហមេធាវីការពារក្តីលោក ខៀវ សំផន សូមទាញចំណាប់អារម្មណ៍អង្គជំនុំជម្រះទៅលើការប្រកាសរបស់អង្គជំនុំជម្រះសាលាដំបូង នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ក្នុងរឿងក្តី *Krajisnić*។ ជាក់ស្តែង អង្គជំនុំជម្រះនេះបានរំឭកថា ភាគីមិនត្រូវយល់ថាវិធាន ៩២ ស្ទួន ជាការស្នើសុំឱ្យដាក់ភស្តុតាងត្រួតគ្នា និងជាន់គ្នាហួសហេតុនោះទេ[52]។

៥០. ក្នុងន័យនេះ មេធាវីការពារក្តីយល់ឃើញថា សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី មិនបានគោរពតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះ នៅក្នុងសេចក្តីសម្រេច ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ សំដៅធានាបាននូវប្រសិទ្ធភាពនៃនីតិវិធី និងការគោរពសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីឆាប់រហ័ស និងប្រកបដោយយុត្តិធម៌។ យ៉ាងណាមិញ ដោយសារតែការធ្វេសប្រហែសក្នុងការជ្រើសសម្រាំងឯកសារក្នុងបញ្ជីរបស់ខ្លួន សហព្រះរាជអាជ្ញាបានខកខានក្នុងការបំពេញកាតព្វកិច្ចនៃវីរិយភាព។ ប្រសិនបើគ្មានការកែតម្រូវពីសំណាក់ភាគីដែលបានស្នើសុំដាក់កំណត់ហេតុស្តាប់ចម្លើយទាំងនេះ ឬពីសំណាក់អង្គជំនុំជម្រះផ្ទាល់នោះទេ ការខកខាននេះនឹងនាំឱ្យមានការពន្យារពេលនីតិវិធីដោយគ្មានប្រយោជន៍ និងមិនសមហេតុផល ហើយធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់លោក ខៀវ សំផន។

## គ. ការសង្កេតលើតម្លៃជាភស្តុតាងនៃកំណត់ហេតុស្តាប់ចម្លើយ ដែលសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី បានស្នើ

៥១. ជាបឋម ពាក់ព័ន្ធនឹងកំណត់ហេតុស្តាប់ចម្លើយ ដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត និងមានរៀបរាប់ក្នុងសំណើ ចុះថ្ងៃទី ១៥ ខែ មិថុនា ថ្ងៃទី ០៥ ខែ កក្កដា

[51] ក្នុងន័យនេះ សូមមើល *រដ្ឋអាជ្ញា ទល់នឹង Galić សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ ពាក់ព័ន្ធនឹងវិធាន ៩២ ស្ទួន (គ)* រឿងក្តីលេខ IT-98-29-AR73.2 ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០២ កថាខណ្ឌ ១២។

[52] *រដ្ឋអាជ្ញា ទល់នឹង Krajisnić ដីកាពាក់ព័ន្ធនឹងសំណើរបស់រដ្ឋអាជ្ញាសុំឱ្យទទួលយកភស្តុតាង យោងតាមវិធាន ៩២ ស្ទួន* រឿងក្តីលេខ IT -000-39-T ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៤ ទំព័រ ២ កំណត់សម្គាល់ជើងទំព័រ ៥។

និងថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ មេធាវីការពារក្ដីលោក ខៀវ សំផន បានលើកឡើងរួចហើយពីអត្ថិភាពនៃកំណត់ហេតុ ៧៩ ដែលគ្មានខ្សែអាត់ ហើយបានជម្រាបជូនអង្គជំនុំជម្រះ តាមរយៈសារណាមុនៗរបស់ខ្លួន[53]។

៥២. ក៏ប៉ុន្តែ អង្គជំនុំជម្រះបានបញ្ជាក់ថា អង្គជំនុំជម្រះនឹងទម្លាក់ចោលសច្ចធារណ៍នៃភាពអាចជឿទុកចិត្តបាននៃកំណត់ហេតុស្ដាប់ចម្លើយទាំងនេះ ប្រសិនបើរកឃើញថាមានភាពផ្ទុយគ្នាច្រើនដងច្បាស់ក្រឡែត និងអាចជឿជាក់បាន រវាងកំណត់ហេតុស្ដាប់ចម្លើយសាក្សី និងខ្សែអាត់[54]។ ដូច្នេះ ការទទួលយកជាភ័ស្តុតាងនូវកំណត់ហេតុស្ដាប់ចម្លើយគ្មានខ្សែអាត់ ស្មើនឹងកាត់ផ្ដាច់ពីមេធាវីការពារក្ដីនូវមធ្យោបាយក្នុងការជំទាស់ឱ្យបានច្បាស់លាស់គ្រប់គ្រាន់។ ហេតុដូច្នេះ មេធាវីការពារក្ដីលោក ខៀវ សំផន សូមជំទាស់ទៅនឹងកំណត់ហេតុស្ដាប់ចម្លើយគ្មានខ្សែអាត់ ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត។

៥៣. ម្យ៉ាងវិញទៀត មេធាវីការពារក្ដីលោក ខៀវ សំផន សូមរំឭកថា អង្គជំនុំជម្រះបានសម្រេចថា ក្នុងករណីខ្លះ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និងកំណត់ហេតុស្ដាប់ចម្លើយ ដែលធ្វើឡើងដោយអង្គភាពផ្សេងក្រៅពី អ.វ.ត.ក អាចដាក់ឱ្យពិភាក្សាដេញដោលបាន ក៏ប៉ុន្តែ អង្គជំនុំជម្រះបានគូសបញ្ជាក់ថា ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និងកំណត់ហេតុស្ដាប់ចម្លើយទាំងនេះ នឹងមិនទទួលបានសច្ចធារណ៍នៃភាពពាក់ព័ន្ធ និងភាពអាចជឿទុកចិត្តបាន នោះទេ[55]។

៥៤. ដូចមេធាវីការពារក្ដីលោក ខៀវ សំផន បានគូសបញ្ជាក់រួចហើយ យោងទៅលើភាពមន្ទិលសង្ស័យដែលមានរួចហើយលើភាពអាចជឿទុកចិត្តបាននៃខ្លឹមសារកំណត់ហេតុស្ដាប់ចម្លើយ ដែលធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត និងយោងទៅលើរយៈពេលដែលភាគីត្រូវការដើម្បីជំទាស់ទៅនឹងការដាក់ឱ្យពិភាក្សាដេញដោល ជាការមិនសមទំនងទេដែលសហព្រះរាជអាជ្ញា និង

[53] មតិគាំទ្រសំណើរបស់លោក អៀង សារី E221 និងស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូងឱ្យបង្គាប់ដល់សហព្រះរាជអាជ្ញាធ្វើការកែតម្រូវបញ្ជីសក្ខីកម្មជាលាយលក្ខណ៍អក្សរ ដែលសហព្រះរាជអាជ្ញាមានបំណងដាក់បញ្ចូលក្នុងការពិភាក្សាដេញដោលជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ ឯកសារ E223 ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ ២១។

[54] សេចក្ដីសម្រេច ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ២៧។

[55] ដូចយោងខាងលើ កថាខណ្ឌ ២៩។

ដើមបណ្តឹងរដ្ឋប្បវេណី ដាក់បន្ថែមកំណត់ហេតុស្តាប់ចម្លើយរាប់រយទៀត ដែលធ្វើឡើងដោយការិយាល័យរបស់ខ្លួន[56] ផ្នែកគាំពារជនរងគ្រោះ ឬអង្គភាពឯករាជ្យ[57]។ លើសពីនេះទៅទៀត "ការបកប្រែ" នៃកំណត់ហេតុស្តាប់ចម្លើយទាំងនេះ ជាភាសាអង់គ្លេស និងបារាំង ភាគច្រើនជាសេចក្តីសង្ខេបប៉ុណ្ណោះ ហើយភាពអាចជឿទុកចិត្តបានត្រូវបានជំទាស់តវ៉ាខ្លាំងជាងច្បាប់ដើមទៅទៀត។ ដូច្នេះ មេធាវីការពារក្តីលោក ខៀវ សំផន ស្នើឱ្យអង្គជំនុំជម្រះបដិសេធភស្តុតាងទាំងនេះ ដោយសារតែគ្មានភាពអាចជឿទុកចិត្តបានគ្រប់គ្រាន់ ឬបើមិនដូច្នោះទេ ស្នើសុំឱ្យផ្តល់តម្លៃជាភស្តុតាងតិចតួចបំផុត។

៥៥. **អាស្រ័យហេតុនេះ** មេធាវីការពារក្តីលោក ខៀវ សំផន ស្នើសុំអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

- **សម្រេច និងប្រកាស** មិនទទួលយកកំណត់ហេតុស្តាប់ចម្លើយ ពាក់ព័ន្ធនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ និងសមាជិកផ្សេងទៀតនៃសហឧក្រិដ្ឋកម្មរួមដែលបានចោទប្រកាន់ រួមទាំងអំពើរបស់អង្គភាពធ្វើសេចក្តីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជា
- **សម្រេច និងប្រកាស** មិនទទួលយកកំណត់ហេតុស្តាប់ចម្លើយ ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារ ដោយហេតុថាកំណត់ហេតុស្តាប់ចម្លើយទាំងនេះមានបញ្ហា "ចម្រូងចម្រាស់" រវាងភាគីនៃរឿងក្តី និងសំដៅបង្ហាញអំពីធាតុផ្សំអត្តនោម័តនៃទម្រង់នៃការចូលរួម ដែលតាមរយៈនោះ សហព្រះរាជអាជ្ញាមានបំណងឱ្យសហជនជាប់ចោទទទួលខុសត្រូវ
- **សម្រេច និងប្រកាស** មិនទទួលយកកំណត់ហេតុស្តាប់ចម្លើយ ដែលសំដៅបង្ហាញធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពីព្រោះនេះជាបញ្ហាចម្រូងចម្រាស់រវាងភាគីនៃរឿងក្តី ដោយហេតុថាមេធាវីការពារក្តីត្រូវតែមានលទ្ធភាពសួរដេញដោលម្ចាស់ចម្លើយបាន

---

[56] សំណើបន្ថែម (ឯកសារ E96/8) កថាខណ្ឌ ២៦។ ពាក់ព័ន្ធនឹងបញ្ហានេះ សហព្រះរាជអាជ្ញាបញ្ជាក់ថា "កំណត់ហេតុខ្លះត្រូវបានធ្វើកំណត់ត្រាដោយអ្នកស៊ើបអង្កេតរបស់ការិយាល័យសហព្រះរាជអាជ្ញា ហើយបើទោះបីជាអ្នកស៊ើបអង្កេតមិនតម្រូវឱ្យមានអព្យាក្រឹតភាពដូចសហចៅក្រមស៊ើបអង្កេត នៅក្នុងស៊ើបអង្កេត ក៏ដោយ ក៏កំណត់ហេតុទាំងនេះត្រូវតែអាចដាក់បញ្ចូលឱ្យពិភាក្សាដេញដោល យោងតាមសំណើនេះ បានដែរ"។

[57] សហព្រះរាជអាជ្ញាមានបំណងដាក់ឱ្យពិភាក្សាដេញដោលនូវកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤០៩ នាក់ (ស្មើនឹង ១២២២ ឯកសារ) ព្រមទាំងកំណត់ហេតុចំនួន ៣២០ ដែលចងក្រងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងសាលាសិក្សាអំពីបូព៌ាប្រទេស និងអាហ្វ្រិក (ស្មើនឹង ៤២០ ឯកសារ)។

- **សម្រេច និងប្រកាស** មិនទទួលយកភ្លាមៗនូវកំណត់ហេតុស្តាប់ចម្លើយគ្មានខ្សែអាត់ ដែលធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត
- **សម្រេច និងប្រកាស** មិនទទួលយកកំណត់ហេតុស្តាប់ចម្លើយទាំងអស់ ដែលធ្វើឡើងដោយអង្គភាពផ្សេងក្រៅពីការិយាល័យសហចៅក្រមស៊ើបអង្កេត និងមានទម្រង់ជាសេចក្តីសង្ខេប ឬបើមិនដូច្នេះទេ គប្បីផ្តល់តម្លៃជាភស្តុតាងតិចតួចបំផុតដល់កំណត់ហេតុស្តាប់ចម្លើយទាំងនេះ។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន | ទីក្រុងភ្នំពេញ | |
| | មេធាវី Anta GUISSÉ | ទីក្រុងប៉ារីស | |
| | មេធាវី Arthur VERCKEN | ទីក្រុងប៉ារីស | |
| | មេធាវី Jacques VERGÈS | ទីក្រុងប៉ារីស | |